**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

********

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**លេខ ០២.០៤៦/០៧ គជប.អគ្គ.ពស**

ភ្នំពេញ ថ្ងៃទី ៨ ខែ មីនា ឆ្នាំ ២០០៧

# សេចក្តីជូនដំណឹង

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត សូមប្រកាសជូនដំណឹងដល់បណ្តាគណបក្សនយោបាយ អង្គការមិនមែនរដ្ឋាភិបាលជាតិ-អន្តរជាតិ និងប្រព័ន្ធផ្សព្វផ្សាយព័ត៌មានជាតិ និងអន្តរជាតិទាំងអស់ ឱ្យបានជ្រាបថា **នៅថ្ងៃ ច័ន្ទ ទី ១២ ខែ មីនា ឆ្នាំ ២០០៧ វេលាម៉ោង ៨:៣០ ព្រឹក** គ.ជ.ប នឹងធ្វើការដឹកជញ្ជូនសន្លឹកឆ្នោត ដែលបានវេចខ្ចប់រួចចំនួន **៦** ខេត្ត ក្រុង ចុងក្រោយ ចេញពីរោងពុម្ពស្ថិតនៅផ្ទះលេខ **៩** ផ្លូវលេខ **៣៤៥** សង្កាត់ បឹងកក់ទី ១ ខណ្ឌទួលគោក រាជធានី ភ្នំពេញ ទៅកាន់ឃ្លាំង គ.ជ.ប ស្ថិតនៅតាមបណ្តោយផ្លូវជាតិលេខ **៥** សង្កាត់គីឡូម៉ែត្រលេខ **៦** ខណ្ឌ ឫស្សីកែវ រាជធានី ភ្នំពេញ (ក្នុងមជ្ឈមណ្ឌលឃ្លាំងពាណិជ្ជកម្មគីឡូម៉ែត្រលេខ ៦) ។

ទន្ទឹមនឹងនេះ គ.ជ.ប សូមអញ្ជើញអ្នកសង្កេតការណ៍បោះឆ្នោតជាតិ-អន្តរជាតិ តំណាងគណបក្សនយោបាយ និងអ្នកសារព័ត៌មានទាំងអស់ ចូលរួមពិនិត្យមើលការគ្រល់ និងទទួលសម្ភារៈឯកសារបោះពុម្ព (ហ្វីលបោះពុម្ពសន្លឹកឆ្នោត ......................) ពីរោងពុម្ពជូន គ.ជ.ប បន្ទាប់មកសូមអញ្ជើញតាមឃ្លាំមើលការដឹកជញ្ជូនសន្លឹកឆ្នោតចេញពីរោងពុម្ពទៅកាន់ឃ្លាំង គ.ជ.ប ។

សេចក្តីជូនដំណឹងនេះ ចាត់ទុកជាការអញ្ជើញអ្នកសង្កេតការណ៍បោះឆ្នោតជាតិ-អន្តរជាតិ តំណាងគណបក្សនយោបាយ និងអ្នកសារព័ត៌មានទាំងអស់ ចូលរួមកុំបីខាន ។

**សូមអរគុណ !**

ព័ត៌មានបន្ថែម សូមទំនាក់ទំនងផ្នែកព័ត៌មាន ទូរស័ព្ទលេខ៖ 012 855 018 & Fax 023 214 374